ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បទបង្ហាញស្តីពី

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣















រៀបចំដោយៈ
នាយកដ្ឋានផែនការ និងស្ថិតិ, កសក
ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម
# ២០១៩-២០២៣





# មាតិកា

១ ស្ថានភាពទូទៅ និងលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

២ បញ្ហាប្រឈម និង កាលានុវត្តភាព

៣ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣

១

# ស្ថានភាពទូទៅ និងលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
វិស័យកសិកម្ម ២០១៤-២០១៨

# ស្ថានភាពទូទៅនៃវិស័យកសិកម្ម

- វិស័យកសិកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។
- ការធ្វើទំនើបកម្មវិស័យកសិកម្ម ដែលជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យ៉ាងច្បាស់ គឺ ការប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម ឈានទៅរកដំណាក់កាលថ្មីដែលផ្ដោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម
- ផ្អែកលើចក្ខុវិស័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ដោតការយកចិត្តទុកដាក់ជាសំខាន់លើ៖
  - ការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម
  - ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើដល់ផលិតកម្មកសិកម្ម
  - បង្កើនគុណភាពនៃការផ្ដល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ

# ស្ថានភាពទូទៅនៃវិស័យកសិកម្ម

- ការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងធន់នឹងការប្រែប្រួលអាកាសធាតុ
- ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម
- ការពង្រឹងសហគមន៍កសិកម្ម និងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន
- ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
- ការពង្រឹងការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្របក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។

# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

## ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិឆ្នាំ២០១៤-២០១៨

Share ( % ) of Agriculture in GDP, 2014-2018 ( At current prices )



# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

## តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មឆ្នាំ២០០៩-២០១៨ (គិតតាមថ្លៃបច្ចុប្បន្ន)



# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

## ការចូលរួមចំណែករបស់អនុវិស័យក្នុងផលទុនជាតិឆ្នាំ២០១៤-២០១៨



# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

## ការចូលរួមចំណែកនៃអនុវិស័យកសិកម្មឆ្នាំ២០១៤-២០១៨ (គិតតាមថ្លៃបច្ចុប្បន្ន)




| | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| ដំណាំ Crops | 59.4% | 59.5% | 59.0% | 58.5% | 58.1% |
| សត្វ Livestock & Poultry | 11.3% | 11.3% | 11.3% | 11.2% | 11.1% |
| ជលផល Fisheries | 22.2% | 22.3% | 22.9% | 23.5% | 24.0% |
| ព្រៃឈើ Forestry & Logging | 7.0% | 6.9% | 6.8% | 6.8% | 6.7% |

# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

## ប្រៀបធៀបកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច

| កម្លាំងពលកម្ម | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៣ | | | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី |
| ចំនួនពលកម្មសរុប (ពាន់នាក់) | ៧ ៩៥១ | ៤ ០៦៨ | ៣ ៨៨២ | ១០ ៤១៦ | ៥ ០៥៦ | ៥ ៣៦០ |
| កសិកម្ម (%) | ៤៨,៧ | ៤៧,៤ | ៥០,០ | ៣៧,០ | ៣៥,១ | ៣៩,០ |
| ឧស្សាហកម្ម (%) | ១៩,៩ | ២០,៥ | ១៩,២ | ២៦,២ | ២៧,៣ | ២៥,១ |
| សេវាកម្ម (%) | ៣១,៥ | ៣២,១ | ៣០,៨ | ៣៦,៨ | ៣៧,៦ | ៣៥,៩ |
| ផ្សេងៗ | - | - | - | - | ០,១ | - |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨










# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

## ផលិតកម្មដំណាំសាកវប្បកម្មឆ្នាំ២០១៤-២០១៨








# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨








# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨












- ការនាំចេញផលិតផលកសិកម្មសរុបបានកើនឡើងខ្លាំងចាប់ពីឆ្នាំ ២០១៤គឺពី៣,៤៤លានតោន ដល់៤,២៣លានតោននាឆ្នាំ២០១៨
- ការនាំចេញអង្ករផ្លូវការមានសន្ទុះកើនខ្លាំងក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ (កើនឡើងពី១២,៦ពាន់តោននាឆ្នាំ២០០៩ ដល់៦២៦,២ពាន់តោននាឆ្នាំ២០១៨)

# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨




- ការកើនឡើងអត្រាផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម (១៨%នៅឆ្នាំ២០១៨ និងត្រូវរុញឱ្យបានដល់ ២២ទៅ២៣%នៅឆ្នាំ២០២៣)
- ផលិតកម្មជ្រូកជួបបញ្ហាជំងឺឆ្លង ប៉ះពាល់ដល់ផលិតកម្មក្នុងស្រុក (ត្រូវការអន្តរាគមន៍ជួយដល់កសិករអ្នកចិញ្ចឹម)
- ការចិញ្ចឹមសត្វស្លាបជាលក្ខណៈពាណិជ្ជកម្មមាននិន្នាការទៅមុខល្អប្រសើរ







# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨






កំណើនផលផលមធ្យមប្រចាំឆ្នាំរយៈពេល១០ឆ្នាំកន្លងទៅមានប្រមាន ៦,៨៦% ក្នុងនោះ៖

- នេសាទទឹកសាបកើន ៤%
- នេសាទសមុទ្រ ៦,៤% និង
- វារីវប្បកម្មមាន ២០,៥៣%





# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨







| | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| ចំនួនសហគមន៍ព្រៃឈើសរុប | 485 | 499 | 580 | 610 | 614 |
| ចំនួនសហគមន៍ព្រៃឈើ កសក អនុម័ត | 364 | 404 | 404 | 464 | 484 |







## ២

# បញ្ហាប្រឈម និងកាលានុវត្តភាព

# បញ្ហាប្រឈម និងភាពជានុវត្តភាព

- ផលិតភាពកសិកម្ម និងគុណភាពផលិតផលកសិកម្មនៅមានកម្រិត
- ថ្លៃដើមផលិតកម្មខ្ពស់ ពិបាកប្រកួតប្រជែង
- សមត្ថភាពបច្ចេកទេសនិងការគ្រប់គ្រងសហគមន៍នៅទន់ខ្សោយ
- កង្វះវិនិយោគលើការស្រាវជ្រាវ
- ការធ្វើពាណិជ្ជកម្មកសិកម្ម នៅមានកម្រិត (ភាពទន់ខ្សោយនៃប្រព័ន្ធបញ្ញាទិញពឹងផ្អែកខ្លាំងលើទីផ្សារប្រទេសជិតខាង និងមិនមានការធានាតម្លៃ/ប្រព័ន្ធកិច្ចសន្យាពាណិជ្ជកម្ម របាំងអនាម័យនិងភូតគាមអនាម័យរបស់ប្រទេសនាំចូល ។ល។)

# ផ្នែកទី២៖ បញ្ហាប្រឈម និងភាពលានុវត្តភាព

- ការធ្វើពិពិធកម្មកសិកម្មនៅមានកម្រិតទាប (ខ្វះជំនាញបច្ចេកទេស ទីផ្សារមិនច្បាស់លាស់ ។ល។)
- កង្វះវិនិយោគក្នុងវិស័យកសិកម្ម/កសិ-ឧស្សាហកម្ម ពិសេសការកែច្នៃផលិតផលកសិកម្ម (១៣-១៥% នៃ វិនិយោគឯកជនសរុប)
- រចនាសម្ព័ន្ធគាំទ្រសម្រាប់វិស័យកសិកម្ម មិនទាន់គ្រប់គ្រាន់ និងមិនទាន់មានលក្ខណៈទំនើប
- ប្រព័ន្ធឡូជីស្ទីក នៅមានកម្រិត (ឃ្លាំងស្តុកកសិផល ឡសំងួត ឃ្លាំងត្រជាក់ ការដឹកជញ្ជូន កំពង់ផែ ផ្លូវគមនាគមន៍ ។ល។

# ភាពអនុវត្តភាពសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម

- លទ្ធភាពពង្រីកទីផ្សារខាងក្រៅនៅមានច្រើន (ទីផ្សារចិន អាស៊ាន កូរ៉េ ជប៉ុន អឺរ៉ុប អាមេរិក រុស្ស៊ី)
- សន្ទុះនៃការវិនិយោគឯកជនក្នុងវិស័យនៅមានច្រើន (ពិសេសពីប្រទេសចិននិងអាស៊ាន)
- និន្នាការនៃការបង្កើតកសិដ្ឋានកសិកម្មដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ជាលក្ខណៈពាណិជ្ជកម្មនិងទំនើប មានការកើនឡើងគួរឱ្យកត់សម្គាល់ (សក្តានុពលនៃការពង្រីកបន្ថែមនៅមាន)
- ការកើនឡើងនៃការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់កសិកម្ម (ផ្លូវ ទឹក ភ្លើង ដឹកជញ្ជូន ផែ ។ល។) ដែលរួមចំណែកកាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្ម និងអាចទាក់ទាញការវិនិយោគឯកជន
- គោលនយោបាយផលិតស្បៀងអាហារមានសុវត្ថិភាព ផលិតផលសម្គាល់ភូមិសាស្ត្រ អាចនឹងការការទាក់ទាញអ្នកប្រើប្រាស់ និងពង្រីកការនាំចេញ។

៣

# ផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍វិស័យ
# កសិកម្ម
# ២០១៩-២០២៣



# ចក្ខុវិស័យសម្រាប់កសិកម្មកម្ពុជា

- **ចក្ខុវិស័យ៖ “កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ កម្ពុជា”។**














# គោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម

គោលបំណងគោលនយោបាយរួម

"ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព" ។

# ១.ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

**គោលដៅត្រូវជំរុញគឺ៖**

- ➢ ផលិតផលកសិកម្មសរុបត្រូវជំរុញឲ្យកើនពី**២៨លាន**តោននៅឆ្នាំ២០១៩ ដល់**៣៦លាន**តោននៅឆ្នាំ២០២៣
- ➢ ពិពិធកម្មដំណាំឲ្យកើន៦៣% នៅឆ្នាំ២០១៩ ដល់៦៧% នៅឆ្នាំ២០២៣
- ➢ ផលិតផលដំណាំកសិកម្មនាំចេញនឹងកើនពី៥,៨លានតោននៅឆ្នាំ២០១៩ ដល់៧,៧លានតោននៅឆ្នាំ២០



**ក្រសួងនឹងផ្តោតអាទិភាពខ្ពស់លើ៖**

- ជំរុញទំនើបកម្មកសិកម្មលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យកសិកម្ម កសិដ្ឋានគំរូតាមគោលការណ៍សន្សំសំចៃទឹក យន្តូបនីយកម្មកសិកម្ម
- អនុវត្តគោលការណ៍ GAP សុវត្ថិភាពចំណីអាហារ SPS ធាតុចូលកសិកម្ម គ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ។ល។
- ផលិតកម្មកសិកម្មតាមកិច្ចសន្យា
- បង្កើនការងារពិសោធន៍ ស្រាវជ្រាវ (ពូជ បច្ចេកទេស បច្ចេកវិទ្យាកសិកម្ម ...)
- ពង្រីកការផ្សព្វផ្សាយ និងសហគមន៍កសិកម្ម
- បង្កើនការវិនិយោគឯកជន (PPP) ។ល។











# ២.ការលើកកម្ពស់ផលិតកម្មសត្វនិងសុខភាពសត្វ







<u>គោលដៅត្រូវជំរុញគឺ៖</u>

- **បង្កើនផលិតផលសាច់ឲ្យកើនពី ២៤០ពាន់តោននាឆ្នាំ២០១៨ ដល់ ២៧០ពាន់តោន នៅឆ្នាំ២០២៣**
- **បង្កើនអត្រា (%) នៃការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ឲ្យកើនពី២៣%នាឆ្នាំ២០១៨ ដល់៣០%នៅឆ្នាំ២០២៣**
- **កាត់បន្ថយអត្រាជម្ងឺឆ្លងសត្វឲ្យនៅត្រឹម៥%**

<u>ក្រសួងនឹងផ្តោតអាទិភាពខ្ពស់លើ៖</u>

- **ពង្រឹងផលិតកម្មសត្វ រួមទាំងលើកកម្ពស់ការគ្រប់គ្រង និងការបង្កាត់ពូជសត្វ**
- **ពង្រឹងសុខភាពសត្វ សុខភាពសាធារណៈបសុព្យាបាល និងសុខុមាលភាពសត្វ**
- **ជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ (ប្រភេទពូជនិងបង្កាត់សម្បូនិម្មិត ចំណី បសុឱសថ....)**
- **ពង្រឹងសេវាផ្សព្វផ្សាយស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងអភិវឌ្ឍន៍ទីផ្សារ**
- **ពង្រឹងការអនុវត្តប្រព័ន្ធជីវសុវត្ថិភាព និងលើកកម្ពស់គុណភាព សុវត្ថិភាពសាច់សត្វ**
- **ពង្រឹងនិងទប់ស្កាត់ចលនាសត្វឆ្លងដែនខុសច្បាប់**

# ៣.ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

<u>គោលដៅត្រូវជំរុញគឺ៖</u>

- **រក្សាការចាប់ផលនេសាទពីធម្មជាតិក្នុងរង្វង់៦០០ពាន់តោនក្នុងមួយឆ្នាំ**
- **បង្កើនផលវារីវប្បកម្មធៀបនឹងផលផលិតផលលផលសរុបឲ្យបាន៤៩% ឆ្នាំ២០២៣**

<u>ក្រសួងនឹងផ្តោតអាទិភាពខ្ពស់លើ៖</u>

- **ពង្រឹងការគ្រប់គ្រងធនធានជលផលធម្មជាតិ ដោយយកចិត្តទុកដាក់លើការបង្ក្រាបបទល្មើសនេសាទ និងការអភិរក្ស**
- **ជំរុញវារីវប្បកម្ម ទាំងទឹកសាបនិងទឹកប្រៃ ដើម្បីបំពេញសេចក្តីត្រូវការទីផ្សារក្នុងស្រុក**
- **ពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ (ពិសេសការបង្កើនទុនអាជីវកម្មនិងគ្រប់គ្រង)**
- **ជំរុញការស្រាវជ្រាវជលផល ទាំងទឹកសាបនិងទឹកប្រៃ**
- **បង្កើនការគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាព ដោយពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល**







# ៤.ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ



<u>គោលដៅត្រូវជំរុញគឺ៖</u>

- ➢ បរិមាណផលឈើដាំឱ្យសម្រេចបាន៣០០ពាន់ម៉ែត្រគូបនៅឆ្នាំ២០២៣
- ➢ ចំណូលសហគមន៍ព្រៃឈើឱ្យកើន១៨%នៅឆ្នាំ២០២៣

<u>ក្រសួងនឹងផ្តល់អាទិភាពខ្ពស់លើ៖</u>

- ➢ ជំរុញការដាំស្តារព្រៃឈើក្នុងរង្វង់ឱ្យបាន១០ ០០០ហត/ឆ្នាំ
- ➢ បង្កើនចំណូលសហគមន៍ព្រៃឈើ តាមរយៈកសិ-រុក្ខកម្ម
- ➢ ពង្រឹងការអនុវត្តច្បាប់ និងទប់ស្កាត់បទល្មើសព្រៃឈើ
- ➢ ជំរុញការអភិវឌ្ឍចម្ការឈើដាំ និងរុក្ខវប្បកម្ម
- ➢ ពង្រឹងការគ្រប់គ្រង និងថែទាំសត្វព្រៃ
- ➢ ជំរុញការស្រាវជ្រាវកិច្ចការព្រៃឈើនិងសត្វព្រៃ









# ៥.ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស

គោលដៅត្រូវជំរុញគឺ៖

- ជំរុញការអនុវត្តថវិកាកម្មវិធីឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- លើកកម្ពស់និស្សិតឲ្យទទួលបានការងារធ្វើនិងបង្កើតមុខរបរថ្មីក្រោយបញ្ចប់ការសិក្សា
- ពង្រឹងការអនុវត្តអនុសាសន៍កែលម្អប្រសិទ្ធភាពការងារនិងសមត្ថភាពគ្រប់គ្រងរបស់អង្គភាពជំនាញ

ក្រសួងនឹងផ្តល់អាទិភាពខ្ពស់លើ៖

- **ការពង្រឹងស្ថាប័ន៖** ជំរុញការគ្រប់គ្រងអង្គភាពជំនាញក្រោមឱវាទក្រសួង ឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគោលនយោបាយ សម្រាប់អភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព។

# ៥.ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស

ក្រសួងនឹងផ្តល់អាទិភាពខ្ពស់លើ៖

- **ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ៖** បង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រ ពង្រឹងប្រព័ន្ធព័ត៌មាននិងទីផ្សារកសិកម្ម ការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈនិងឯកជន ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ ការធ្វើអធិការកិច្ចសវនកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាគាំទ្រពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។
- **ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម៖** បង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យានិងរបកគំហើញថ្មីៗ សំដៅពង្រឹងនិងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

# គម្រោងការធនធានថវិកា២០១៩-២០២៣

- តម្រូវការធនធានហិរញ្ញវត្ថុសម្រាប់រយៈពេល០៥ឆ្នាំ៖
  - ថវិកាប៉ាន់ស្មានប្រមាណ **៣ ៨៤២ ពាន់លានរៀល** ក្នុងនោះ
    - ថវិកាចរន្តចំនួន ១ ៣៥៩ ពាន់លានរៀល
    - ថវិកាមូលធនចំនួន ២ ៤៨២ ពាន់លានរៀល


សូមអរគុណ!!!